# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង

លេខ០២ ខែកុម្ភៈ ឆ្នាំ២០២៤



ហ្វេសប៊ុកផេក៖ វិទ្យាល័យ ហ៊ុនសែន ពាមជីកងជំនាន់ថ្មី
លេខទូរសព្ទ៖ 096 7273 921/ 087 609 156
គេហទំព័រ www.pck.ngs.edu.kh
អ៊ីម៉ែល៖ ngspckhighschool@gmail.com


## មាតិកា


- សកម្មភាពសិស្សរៀនមុខវិជ្ជាភាសាខ្មែរក្នុងបណ្ណាល័យ
- កម្មវិធីជជែកដេញដោលយុវជន
- សកម្មភាពប្រជុំក្លឹបប្រវត្តិសាស្ត្រ
- ប្រឡងប្រចាំខែកុម្ភៈ
- ការប្រមូលផលដំណាំនៅក្នុងសួនបំណិនជីវិត


## សកម្មភាពសិស្សរៀនមុខវិជ្ជាភាសាខ្មែរក្នុងបណ្ណាល័យ

ពាមជីកង៖នៅថ្ងៃព្រហស្បតិ៍ ៧រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ អ្នកគ្រូ ហុង សុភត្រ្តា បានដឹកនាំសិស្សានុសិស្សថ្នាក់ទី9B1, 9B2 ម៉ោងភាសាខ្មែរសិក្សាអត្ថបទរឿងកូលាបបៃលិនតាមរយៈវីដេអូនៅក្នុងបណ្ណាល័យ។ ជាមួយគ្នានេះដែរ ការនាំសិស្សចូលរៀននៅក្នុងបណ្ណាល័យ គឺដើម្បីផ្លាស់ប្តូរបរិយាកាសសិក្សា ងាយស្រួលឱ្យសិស្សនុសិស្សរកឯកសារមេរៀនបន្ថែម និងងាយស្រួលមើលវីដេអូមេរៀនជាមួយទូរទស្សន៍ឆ្លាតវៃ។











# កម្មវិធីជជែកដេញដោលយុវជន

ពាមជីកង៖ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង១រសៀល ក្លឹបជជែកដេញដោលនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រកួតជុំទី១ នៅអគារធនធាននៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង។ ការជជែកដេញដោលយុវជននេះដែរ ធ្វើឡើងដើម្បី ជួយឱ្យយុវជនទទួលបានចំណេះដឹងទូលំទូលាយ និងបង្កើតឱកាសក្នុងការបង្ហាញខ្លួនក្នុងសង្គម, ទទួលបានចំណេះដឹង ដើម្បីដោះស្រាយបញ្ហាដោយត្រឹមត្រូវ និងដោយសន្តិវិធី ថែមទាំងមានការផ្លាស់ប្តូរផ្នត់គំនិត និងពង្រីកទស្សនៈវិស័យជាវិជ្ជមាន។













# សកម្មភាពប្រជុំក្លឹបប្រវត្តិសាស្ត្រ

ពាមជីកង៖ នៅថ្ងៃសៅរ៍ ៨កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤ ក្លឹបប្រវត្តិសាស្ត្របានជួបជុំគ្នាដើម្បីប្រជុំដែលមានលោកគ្រូដឹកនាំក្លឹប ប្រធានក្លឹប និងសមាជិកទាំងអស់ដើម្បីបានជួបសំណេះសំណាលគ្នាទាក់ទងនិងក្លឹបសិក្សាប្រវត្តិសាស្ត្រ។

ការជួបប្រជុំគ្នានេះធ្វើឡើងក្នុងគោលបំណង៖ និយាយពីដំណើរការនៃប្រធានបទថ្មីសម្រាប់ឆ្នាំសិក្សា2024








# ប្រឡងប្រចាំខែកុម្ភៈ



ពាមជីកង៖ នៅថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រឡងប្រចាំខែកុម្ភៈ ដល់សិស្សានុសិស្សគ្រប់កម្រិតថ្នាក់សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ នៅតាមអគារនីមួយៗដោយមានភាពតឹងរឹងបំផុត ហើយនៅតាមបន្ទប់ប្រឡងមានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារប្រឡងនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារចំនួនមួយនាក់។ សិស្សានុសិស្សបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។









# ការប្រមូលផលដំណាំនៅក្នុងសួនបំណិនជីវិត



ពាមជីកង៖ នៅថ្ងៃពុធ ៤រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ សិស្សានុសិស្សក្នុងម៉ោងបំណិនជីវិត ដែលបង្រៀនដោយលោកគ្រូ អ៊ី លឹមហៅ បានចាប់ផ្ដើមប្រមូលផលដំណាំដែលពួកគាត់បានដាំក្នុងម៉ោងបំណិនជីវិត ផលដំណាំដែលពួកគាត់ប្រមូលផលពេលនេះមានដូចជា ផ្កាខាត់ណា និងស្ពៃក្ដោប។ ហើយដំណាំទាំងនេះត្រូវបានកាត់យកទៅដាក់លក់ ដែលមានអ្នកទិញដូចជា លោកគ្រូ អ្នកគ្រូ និងអ្នកភូមិជាដើម។ បន្ទាប់ពីដាក់លក់អស់ ប្រាក់ដែលពួកគាត់ទទួលបានពីការលក់ ពួកគាត់ក៏បានយកប្រាក់ទាំងនោះយកទៅទិញគ្រាប់ពូជបន្ថែមទៀត ដើម្បីទុកដាំនៅពេលក្រោយៗទៀត។









